

# សហគមន៍ចូលរួមក្នុងការគ្រប់គ្រងធនធានជលផល

ករណីសិក្សា

នៅភូមិត្បូងខ្លា និងអូរម្រះក្នុងខេត្តស្ទឹងត្រែង

នៃព្រះរាជាណាចក្រកម្ពុជា


ស្រាវជ្រាវ និងចងក្រងដោយៈ

លោក ឈៃ គីមសេង

លោក ឌៃ ស៊ីវ៉ាបូ

សំរបសំរួលដោយៈ

លោក អ៊ុល គីមស៊ា


២០០២

# សហគមន៍ចូលរួមក្នុងការគ្រប់គ្រងធនធានជលផល

**ករណីសិក្សា**

នៅភូមិត្បូងខ្លា និងអូរស្រះក្នុងខេត្តស្ទឹងត្រែងនៃព្រះរាជាណាចក្រកម្ពុជា

**ស្រាវជ្រាវ និងចងក្រងដោយៈ**

លោក ខៃ ស៊ីរ៉ាបូ

លោក ថៃ គឹមសេង

**អ្នកសំរបសំរួលដោយៈ**

លោក អ៊ុល គឹមសា

**២០០២**

ករណីសិក្សានេះ មានគោលបំណងចងក្រងជាឯកសារអំពីការចូលរួមគ្រប់គ្រងលើធនធានជលផលរបស់ អ្នកភូមិត្បូងខ្លា និងអូរស្រះក្នុងខេត្តស្ទឹងត្រែង។ ធនធានជលផល គឺជាប្រភពអាហារចំបងសំរាប់ការរស់នៅរបស់ប្រជាជនក្នុងស្រុក ពិសេសប្រជាពលរដ្ឋប្រមាណ ៩០ ភាគរយដែលកំពុងរស់នៅតំបន់ជនបទត្រូវការត្រីជាចាំបាច់។ កន្លងមកក្នុងកំឡុងឆ្នាំ ១៩៨៥ ដល់ ១៩៩៨ តំបន់នេសាទនៅក្នុងខេត្តស្ទឹងត្រែង បានប្រឈមមុខនិងការបំផ្លាញធនធានជលផលយ៉ាងខ្លាំង។ ការអូសបន្លាយនៃសង្គ្រាមស៊ីវិល ការធ្វើអាជីវកម្មលើធនធានហួសកំរិត សំពាធពីអ្នកខាងក្រៅ កង្វះខាតការគ្រប់គ្រង និងការអនុវត្តច្បាប់នៅមានកំរិត។ ហេតុនេះ ការថយចុះនៃធនធានត្រីបានបណ្តាលអោយជះឥទ្ធិពលយ៉ាងខ្លាំងលើជីវភាពរស់នៅប្រចាំថ្ងៃរបស់អ្នកភូមិ ព្រមទាំងបានបង្កើនភាពក្រីក្រថែមទៀត។

ចំពោះហេតុផលទាំងនេះ បានជំរុញអោយសហគមន៍មូលដ្ឋានចូលរួមរៀបចំសហគមន៍នេសាទ ដោយមានការឧបត្ថម្ភពីអង្គការ អូស៊ីអេអេ ដែលបានសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(ការិយាល័យជលផល)។ ដូចនេះផងដែរ សហគមន៍មូលដ្ឋានមានការចាប់អារម្មណ៍ក្នុងការថែរក្សានូវធនធានទាំងនេះ ពីព្រោះថាបានបង្ហាញសញ្ញានៃការកាត់បន្ថយនូវបទល្មើសនេសាទ មានតួនាទី និងការទទួលខុសត្រូវច្បាស់លាស់ ព្រមទាំងបានទទួលផលប្រយោជន៍ពីការរៀបចំសហគមន៍នេសាទនេះ ពិសេស សហគមន៍មូលដ្ឋានយល់ដឹងនូវការប្រើប្រាស់ធនធានត្រីប្រកបដោយនិរន្តភាព ព្រមទាំងបានចូលរួមក្នុងការគ្រប់គ្រងធនធានជលផលទៀតផង។

OCAA RECOFTC IDRC CRDI CANADA Oxfam America WWF

**ស្រាវជ្រាវ និងចងក្រងដោយ :**

លោក ខៃ ស៊ីវ៉ាបូ

មន្ត្រីសមាសភាគីជាមួយអង្គការសហគមន៍ជំនួយបរទេស

លោក ថៃ គីមសេង

មន្ត្រីជំនួយការនៃអង្គការសហគមន៍ជំនួយបរទេស

**អ្នកសំរេចសំរួលដោយ :**

លោក អ៊ុល គឹមសា

មន្ត្រីការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទនៃនាយកដ្ឋានជលផល

សមាសភាគីជាមួយគំរោងស្តីពី " ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម"

នៃអង្គការ WWF

**ទីប្រឹក្សា :**

កញ្ញា ហ៊ូ កល្យាណ

លោក ស្រី មារ៉ូណា

លោក ឆួម យ៉េង

លោកធូ ប៊ីខាហ្សិន

**អ្នកកែសំរួលដោយៈ**

កញ្ញា វេបិកកា គីនណាកិន

លោក កៃន អរ៉ារីន

លោក កៃនមិត វិបឺ

**ឧបត្ថម្ភដោយអង្គការៈ**

-សហគមន៍ជំនួយបរទេស

-គំរោងករណីសិក្សា " ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម" នៃអង្គការ WWF

-មជ្ឈមណ្ឌលស្រាវជ្រាវអន្តរជាតិសំរាប់ការអភិវឌ្ឍន៍

-មជ្ឈមណ្ឌលបណ្តុះបណ្តាលសហគមន៍ព្រៃឈើថ្នាក់តំបន់

-អង្គការអុកស្វាមអាមេរិកាំង

# អារម្ភកថា

## ដំណើរការករណីសិក្សា

ដោយទទួលស្គាល់ថា ការគ្រប់គ្រងធនធានដោយសហគមន៍ (CBNRM) គឺជាទស្សនៈ និងការអនុវត្តថ្មីមួយ ចំពោះប្រទេសកម្ពុជា ការចងក្រងឯកសារអំពីបទពិសោធន៍មូលដ្ឋាន និងមេរៀនដែលទទួលនេះបង្កើតចេញជាសមាសភាគសំខាន់មួយនៃការវិភាគ និងការចែករំលែកពត៌មានរវាងសហគមន៍មូលដ្ឋាន គំរោង និងភ្នាក់ងារពាក់ព័ន្ធផ្សេងៗ ដែលធ្វើការទាក់ទង CBNRM នេះ ។

ការចងក្រងករណីសិក្សានេះ គឺជាផ្នែកមួយនៃគំនិតផ្តួចផ្តើមរៀនសូត្រចម្រុះមួយ (ដោយផ្អែកលើគំរូវដ្តរៀនសូត្រដែលជាបទពិសោធន៍មួយ) ដែលមានរយៈពេលចាប់ពីខែ មិថុនា ឆ្នាំ ២០០១ ដល់ ខែវិច្ឆិកា ឆ្នាំ ២០០២ និងអាចមានរយៈពេលយូរជាងនេះទៅទៀត ។ ការបណ្តុះបណ្តាលដំបូងអំពីការសរសេរករណីសិក្សាដែលបានធ្វើឡើងនៅខេត្តសៀមរាបសំរាប់អ្នកអនុវត្តគំរោង CBNRM ជាង ៣០ នាក់ នៅខែកក្កដា ឆ្នាំ ២០០១ ដើម្បីផ្តល់ជំនាញគ្រឹះសំរាប់ការសិក្សាស្រាវជ្រាវ PRA ការវិភាគពត៌មាន ការសរសេរអត្ថបទ និង ចងក្រងឯកសារ ។ ជាលទ្ធផល នៃតម្រូវការខ្ពស់សំរាប់ការងារប្រភេទនេះ វគ្គបណ្តុះបណ្តាលករណីសិក្សាមួយបានធ្វើឡើងនៅ ខែ វិច្ឆិកា ឆ្នាំ ២០០១ នៅខេត្តរតនៈគីរី ដែលមានអ្នកចូលរួមជាង ៤០ នាក់ ដើម្បីបង្កើនជំនាញខាងការស្រាវជ្រាវ និងជំនាញសរសេរអត្ថបទ ដើម្បីផ្តួចផ្តើមបង្កើតជាក្របខ័ណ្ឌការងារដែលជាទស្សនទានមួយសំរាប់ការងារ CBNRM នៅក្នុងប្រទេសកម្ពុជា ។ ជាលទ្ធផលបានមកពីការបណ្តុះបណ្តាលនេះ យើងបានរៀបចំផែនការការងារករណីសិក្សាមួយដែលមានបញ្ចូលទាំងការកំណត់ប្រធានបទ និងសេចក្តីព្រាងគំនិត ។

ករណីសិក្សានេះ គឺជាផ្នែកមួយនៃករណីសិក្សាចំនួន ១០ ធ្វើការផ្តោតទៅលើទាំងបញ្ហាជលផល និងបញ្ហាព្រៃឈើ ដែលបានបង្កើតឡើងនៅក្នុងភូមិសាស្ត្រសំខាន់ ៤ នៃប្រទេសកម្ពុជាដែលមាន តំបន់ខ្ពង់រាប (ខេតរតនៈគីរី និងមណ្ឌលគីរី ) តំបន់ទំនាបកណ្តាល (ខេត្តពោធិសាត និងកំពង់ឆ្នាំង ) តំបន់ទន្លេមេគង្គ ឬ ទន្លេសាប (ខេត្តស្ទឹងត្រែង និងសៀមរាប ) និងតំបន់ឆ្នេរ (ខេត្តកោះកុង និងកំពង់សោម) ។

តាមករណីជាច្រើនសេចក្តីព្រាងលើកទី ១ របស់ករណីសិក្សាទាំង១០ ត្រូវបានបង្កើតឡើងដោយក្រុមស្រាវជ្រាវ និងអ្នកនិពន្ធ ចម្រុះដោយចាប់ពី ខែ មករា ដល់ ខែ មេសា ឆ្នាំ ២០០២ ។ សេចក្តីព្រាងលើកទី ២ ត្រូវបានលើយកមកបង្ហាញដើម្បីទទួលយកនូវការផ្តល់យោបល់ក្នុងពេលធ្វើសិក្ខាសាលា និងសិក្ខាសាលាបូកសរុបដែលបានធ្វើនៅខេត្តកោះកុង ខែ ឧសភា ឆ្នាំ២០០២ ។ នៅពេលនោះ ករណីសិក្សាទាំងនេះត្រូវបានពិនិត្យមើលបកប្រែជាភាសាអង់គ្លេស ហើយបានធ្វើការកែសម្រួលដើម្បីបោះពុម្ព និងផ្សព្វផ្សាយ ។ អ្នកសម្របសម្រួលគំរោងនៅតាមមូលដ្ឋាន ដើរតួនាទីឈានមុខក្នុងការជ្រើសរើសប្រធានបទសម្រាប់ការសិក្សាស្រាជ្រាវ ការប្រមូលពត៌មាន និងការសរសេរអត្ថបទ ។ អ្នកសម្របសម្រួល និងទីប្រឹក្សាថ្នាក់ជាតិផ្តល់ជាជំនួយលើការពិនិត្យមើលគំរោងករណីសិក្សា ការវិភាគពត៌មាន ការបកប្រែ និងការកែសម្រួល ។

ដោយធ្វើការតាមគំនិតផ្តួចផ្តើមនេះ បានផ្តល់ឱ្យអ្នកចូលរួមក្នុងកម្រិតផ្សេងៗគ្នានូវឱកាសរៀនជំនាញបានកាន់តែច្រើន ដើម្បីចែករំលែកបទពិសោធន៍ជាមួយគំរោង និងមនុស្សផ្សេងៗ ដែលធ្វើការខាងការងារ CBNRM នៅទូទាំងប្រទេសកម្ពុជា ។ តាមមធ្យោបាយបែបនេះ គំនិតផ្តួចផ្តើមចងក្រងករណីសិក្សា CBNRM ត្រូវបានគេប្រើជាឧបករណ៍មួយសម្រាប់បង្កើតជាបណ្តាញការងារ និងចែករំលែកមេរៀនដែលទទួលបាន។ ករណីសិក្សាទាំងនេះនឹងត្រូវបានគេចែករំលែកផងដែរ នៅតាមវេទិការនានាដូចជា សិក្ខាសាលា CBNRM ដែលនឹងធ្វើនៅខែ វិច្ឆិកា ឆ្នាំ ២០០២ ។ គេរំពឹងទុកថាលទ្ធផលនេះ នឹងត្រូវបានប្រើប្រាស់ ដើម្បីជាពត៌មានដល់ការបង្កើតគោលនយោបាយទៅថ្ងៃមុខនៅក្នុងប្រទេសកម្ពុជា ។

◆◆◆ ✍ ◆◆◆

# មាតិកាអត្ថបទ

## ការដាក់ចេញនូវសំណើដែលបង្កើតអោយអ្នកភូមិចូលរួមបង្កើតសហគមន៍នេសាទ និងការជួយរៀបចំគ្រប់គ្រងធនធានជលផល


១. សេចក្តីផ្តើម ........................................ ១

២. ប្រវត្តិ ........................................ ១

ក. លក្ខណៈភូមិសាស្ត្រ ........................................ ១

ខ. អ្នកភូមិ និងជីវភាពរស់នៅ ........................................ ១

៣. មូលហេតុដែលនាំអោយសហគមន៍មូលដ្ឋានចូលរួមរៀបចំសហគមន៍នេសាទ ........................................ ២

ក. សកម្មភាពអនាធិបតេយ្យលើផែននេសាទ ........................................ ២

ខ. ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ........................................ ៤

ខ.១ -ខ្សែភ្លើងឆក់ ........................................ ៤

ខ.២ -គ្រឿងផ្ទុះ ........................................ ៥

គ. ផលប៉ះពាល់របស់ជីវភាពសហគមន៍មូលដ្ឋានដែលបណ្តាលមកពីធនធានព្រៃ និងវិស័យផ្សេងៗទៀត ........................................ ៥

ឃ. ជំលោះរវាងអ្នកនេសាទក្នុងភូមិ និងអ្នកនេសាទខាងក្រៅភូមិ ........................................ ៦

ង. ការយល់ឃើញរបស់សហគមន៍មូលដ្ឋានពីការនេសាទ ........................................ ៦

ច. កង្វះខាតនៃការគាំទ្រពីស្ថាប័នជំនាញ និងគោលនយោបាយ ........................................ ៦

ឆ. កិច្ចសហការ និងការគាំទ្ររបស់អង្គការ ........................................ ៧

៤. អត្ថប្រយោជន៍នៃការថែរក្សាសហគមន៍នេសាទដែលបានរៀបចំរួច ........................................ ៧

ក. បទល្មើសនេសាទថយចុះ ........................................ ៧

ខ. ការចូលរួមគ្រប់គ្រងសហគមន៍នេសាទដោយអ្នកភូមិ ........................................ ៨

៥. ភាពច្បាស់លាស់នៃតួនាទី និងភារកិច្ចនៃការគ្រប់គ្រងសហគមន៍នេសាទគណៈកម្មការ និងសមាជិក ........ ៩

ក. -ប្រធានគណៈកម្មការសហគមន៍នេសាទ ........................................ ១០

ខ. -អនុប្រធានគណៈកម្មការ ........................................ ១០

គ. -ផ្នែកផ្សេងៗ ........................................................ ១០

ឃ. -សមាជិកសហគមន៍នេសាទ ........................................................ ១០

ង. -តួនាទីរបស់បុរស-ស្ត្រីក្នុងដំណើរការនៃសហគមន៍នេសាទ ........................................................ ១០

៦. សិទ្ធិ និងការទទួលខុសត្រូវរបស់សហគមន៍មូលដ្ឋានលើធនធានជលផល ........................................................ ១១

៧. ការបង្កើនចំណេះដឹង និងផ្សព្វផ្សាយព័ត៌មាននានាដល់សហគមន៍មូលដ្ឋាន ........................................................ ១១

៨. សន្និដ្ឋាន ........................................................ ១២

៩. អនុសាសន៍ ........................................................ ១២

១០. ប្រវត្តិនៃគំរោងស្តីពី " អង្គការសហគមន៍ជំនួយបរទេស " ........................................................ ១៤

១១. ប្រវត្តិនៃគំរោងករណីសិក្សា: " ការចូលរួមគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម " ........ ១៦

# កត្តាគន្លឹះសំខាន់ៗដែលជំរុញអោយអ្នកភូមិចូលរួមបង្កើតសហគមន៍នេសាទ និងការជួយថែរក្សាធនធានជលផល

## ១. សេចក្តីផ្តើម:

ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិ ជាកត្តាចាំបាច់សំរាប់ធានាបាននូវនិរន្តភាព ហើយជាប្រភពដ៏មានសារៈប្រយោជន៍យូរអង្វែងសំរាប់ផ្គត់ផ្គង់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ពិសេស សំរាប់បងប្អូនជនជាតិភាគតិចដែលកំពុងបានរស់នៅក្នុងខេត្តស្ទឹងត្រែង ។ ជាក់ស្តែង ដូចជាការចូលរួមគ្រប់គ្រងធនធានជលផលតាមបែបសហគមន៍នេសាទក្នុងពេលបច្ចុប្បន្ន ។

មានហេតុផលពីរយ៉ាងដែលជាអត្ថប្រយោជន៍សំរាប់ការរៀបចំសហគមន៍នេសាទ គឺថាប្រជាជនទាំងពីរភូមិនេះ ចូលរួមបង្កើតសហគមន៍នេសាទ ពីព្រោះវាជាចំនុចល្អ ជួយកាត់បន្ថយនូវការធ្លាក់ចុះនៃធនធានជលផលដែលបណ្តាលមកពីសកម្មភាពអាណាធិតេយ្យជាច្រើននៅលើដែននេសាទក្នុងតំបន់នេះ ព្រមទាំងអាចជួយដោះស្រាយជំលោះរវាងអ្នកភូមិ និងអ្នកនេសាទខាងក្រៅ ក្នុងគោលបំណងជំរុញអោយធនធានមាននិរន្តភាពសំរាប់ពេលអនាគត ។ ដោយសារកង្វះខាត ការគ្រប់គ្រងពីស្ថាប័នបច្ចេទេសលើដែននេសាទដែលនៅដាច់ស្រយាល គួបផ្សំគោលនយោបាយ វិស័យជលផលបានធ្វើអោយប្រជាជនចូលរួមក្នុងការរៀបចំសហគមន៍នេសាទ ។ម្យ៉ាងទៀត អ្នកភូមិអាចរៀបចំសហគមន៍នេសាទបាន គឺដោយសារការគាំទ្រ គួបផ្សំនិងកិច្ចសហការយ៉ាងជិតស្និទ្ធរវាងអង្គការ អូស៊ីអេអេ ជាមួយមន្ទីរកសិកម្មខេត្តស្ទឹងត្រែង ពិសេស ការិយាល័យជលផលបានជំរុញអោយមានការបង្កើតសហគមន៍នេសាទក្នុងភូមិនេះ ។

អត្ថប្រយោជន៍នៃការបង្កើតសហគមន៍នេសាទគឺ វាអាចជួយកាត់បន្ថយបទល្មើសនេសាទ បង្កើនការចូលរួមរបស់សហគមន៍ក្នុងដំណើរសហគមន៍នេសាទ ក្នុងនាមស្រ្តី បុរសក្នុងការចូលរួមគ្រប់គ្រងធនធានជលផល កំណត់ពីសិទ្ធិនិងការទទួលខុសត្រូវលើធនធានបានយ៉ាងច្បាស់លាស់ ព្រមទាំងអាចជួយបង្កើនការយល់ដឹង និងទទួលបានចំណេះដឹងស្តីពីប្រព័ន្ធអេកូឡូស៊ីរួមជាមួយការគ្រប់គ្រងធនធានជលផល ។

## ២. ប្រវត្តិ

### ក. លក្ខណៈភូមិសាស្ត្រ

ភូមិត្បូងខ្លា និងអូរម្រះជាតំបន់ភ្នំ និងខ្ពង់រាបដែលសំបូរដោយធនធានធម្មជាតិដែលមានតំលៃសេដ្ឋកិច្ចខ្ពស់ដូចជា ព្រៃឈើ និងធនធានជលផល ។ លើសពីនេះ ភូមិនេះស្ថិតនៅតាមទន្លេមេគង្គមានលក្ខណៈអំណោយផលល្អដោយមានអន្លង់ជ្រៅៗ ថ្មរដិបរដុប កោះតូចៗ ព្រៃលិចទឹក ព្រមទាំងទឹកហូរយ៉ាងខ្លាំងនៅរដូវវស្សាដែលជាឧបសគ្គក្នុងការធ្វើនេសាទដោយប្រើប្រាស់ឧបករណ៍សិប្បកម្មខ្លះ តែផ្ទុយទៅវិញវាមានលក្ខណៈយ៉ាងល្អប្រសើរសំរាប់ជាទីជំរករស់នៅ និងការពងកូនរបស់ពពួកមច្ឆាជាតិ និងវារីសត្វផ្សេងៗ ពិសេស ប្រភេទត្រីមេពូជសំខាន់ៗ ។

### ខ. អ្នកភូមិ និងជីវភាពរស់នៅ

ពីមួយឆ្នាំទៅមួយឆ្នាំ ដង់ស៊ីតេប្រជាពលរដ្ឋមានការកើនឡើងជាលំដាប់ ដោយសារតែមានការអភិវឌ្ឍន៍នៅក្នុងតំបន់នេះ ហើយ ពួកគេរស់នៅតាមដងទន្លេមេគង្គ ដោយពឹងផ្អែកលើមុខរបរសំខាន់ ២ប្រភេទគឺ ធ្វើស្រែ និងការនេសាទ។ ក្រៅពីសកម្មភាព នេះ ពួកគេបានទៅធ្វើចំការ និងប្រមូលអនុផលផ្សេងៗ ដូចជា ការប្រមាញ់សត្វ បន្លែផ្លែឈើព្រៃ រុក្ខជាតិជាឱសថ និងដាំបន្លែតាមដងទន្លេ សំរាប់តំរូវការផ្គត់ផ្គង់ជីវភាពបន្ថែម។



ការធ្វើសំភាសន៍ជាមួយគណៈកម្មការសហគមន៍នេសាទ
និងអាជ្ញាធរមូលដ្ឋាន

ក្នុងចន្លោះឆ្នាំ១៩៦០-១៩៧០ ជារបបសង្គមរាស្ត្រនិយមភូមិត្បូងខ្លា និងអូរម្រះ គឺមានឈ្មោះតែមួយដែលហៅថា ភូមិជ្រោយស្លែង។ ក្នុងជំនាន់នោះ ប្រជាជនភាគច្រើនជាជនជាតិភាគតិច ដែលគេហៅថា ជនជាតិគួយ។ ក្នុងកំឡុងឆ្នាំ១៩៧០-១៩៨០ ជារបបលន់ណុល និងប៉ុលពត ប្រជាជនមួយចំនួនក្នុងស្រុកបានផ្លាស់ប្តូរទីលំនៅពីតំបន់ផ្សេង ចូលមករស់នៅក្នុងទីកន្លែងនេះ បន្ទាប់មកតំបន់នេះ ត្រូវបានចែកជាពីរភូមិ គឺភូមិអូរម្រះ និងត្បូងខ្លា ដែលស្ថិតនៅឃុំអូរម្រះស្រុកសៀមបូក។ វាមានចំងាយប្រមាណ ៥៨ គីឡូម៉ែត្រ ពីទីរួមខេត្តស្ទឹងត្រែង។

បច្ចុប្បន្ន ភូមិពីរនេះមានព្រំប្រទល់រដ្ឋបាលជាប់គ្នា ប្រជាពលរដ្ឋមានសរុបចំនួន ១៥២គ្រួសារ មានដើមកំណើតពីជនជាតិគួយ និងខ្មែរ។ ចំពោះសហគមន៍នេសាទត្បូងខ្លាមានប្រជាជនសរុបចំនួន ១៣៤គ្រួសារ ក្នុងនោះខ្មែរប្រមាណ ៨០គ្រួសារ និង ៥៤គ្រួសារ ជាជនជាតិគួយ និងសហគមន៍នេសាទអូរម្រះមានចំនួន ១៨គ្រួសារ ដែលមានជនជាតិខ្មែរប្រមាណ ១០គ្រួសារ ព្រមទាំងជនជាតិគួយចំនួន ៨គ្រួសារ។ ប្រជាជនក្នុងពីរភូមិប្រមាណ ៩០ភាគរយ ពឹងផ្អែកលើស្រែ-ចំការ និងនេសាទជាមុខរបរចំបង ហើយប្រហែល ១០ភាគរយ ជាអ្នកលក់ដូរ និងជាឈ្មួញ។

## ៣. មូលហេតុដែលនាំអោយសហគមន៍មូលដ្ឋានចូលរួមរៀបចំសហគមន៍នេសាទ

### ក. សកម្មភាពអនាធិបតេយ្យលើដែននេសាទ

ក្នុងកំឡុងឆ្នាំ១៩៨៤ ដល់ ១៩៩៨ បទល្មើសនេសាទតែងតែកើតឡើងជាញឹកញាប់លើដែននេសាទនៃភូមិអូរម្រះ និងត្បូងខ្លា ដើម្បីធ្វើនេសាទប្រភេទត្រីដែលមានតំលៃសេដ្ឋកិច្ច និងប្រភេទសត្វល្អនសំខាន់។ ការនេសាទក្នុងតំបន់នេះ សំរាប់អ្នកភូមិខ្លះបានប្រើប្រាស់ឧបករណ៍លក្ខណៈសិប្បកម្ម ក្នុងការនេសាទនៅរដូវបិតនេសាទ ដោយពុំទាន់បានយល់ច្បាស់លាស់អំពីច្បាប់ជលផល។ លើសពីនេះទៀត អ្នកនេសាទខាងក្រៅបានចូលមកតំបន់នេះ ធ្វើនេសាទដោយឧបករណ៍ហាមឃាត់ដូចជា ការប្រើរំសេវផ្ទុះ ថ្នាំបំពុល គ្រាប់បែក ចរន្តអគ្គិសនី ពីព្រោះថា វាចំណាយដើមទុនតិច ហើយងាយស្រួលប្រមូលផលត្រីបានច្រើនលើសលប់នៅពេលរដូវប្រាំង ពិសេស ប្រភេទត្រីភាគ ច្រើនបានប្រមូលផ្តុំគ្នាក្នុងអន្លង់ធំៗ។